**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤៤០៥ កសក

រាជធានីភ្នំពេញ, ថ្ងៃទី.០៧....ខែ.កក្កដា.ឆ្នាំ ២០១៥

**សូមគោរពជូន**

**-សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**

**-ឯកឧត្តមប្រធានគណៈកម្មការផែនការ សេដ្ឋកិច្ច វិនិយោគ កសិកម្ម បរិស្ថាន និងអភិវឌ្ឍន៍ជនបទនៃព្រឹទ្ធសភា**

**-ឯកឧត្តមប្រធានគណៈកម្មការផែនការ សេដ្ឋកិច្ច វិនិយោគ កសិកម្ម បរិស្ថាន និងអភិវឌ្ឍន៍ជនបទនៃរដ្ឋសភា**

**-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**-ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង**

**-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា**

**-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា**

**-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**

**-ឯកឧត្តមនាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់**

**កម្មវត្ថុ** ÷ របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំឆមាសទី១ ឆ្នាំ២០១៥** និងទិសដៅអនុវត្តបន្ត ។

ន័យដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមផ្ញើជូនសម្តេច ឯកឧត្តម នូវរបាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំឆមាសទី១ ឆ្នាំ២០១៥** ចំនួន០១ច្បាប់ ដើម្បីជូនជ្រាបជាសេចក្តីរាយការណ៍ ។

សូមសម្តេច ឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត វ៉េង សាខុន**

**ចម្លងជូន**
- គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង
- ឯកសារ កាលប្បវត្តិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆមាសទី១ ឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

ក្នុងឆមាសទី១ ឆ្នាំ២០១៥នេះ ស្ថានភាពទឹកភ្លៀងនៅមិនទាន់ធ្លាក់រាយប៉ាយគ្រប់តំបន់ទូទាំងប្រទេសនៅឡើយទេ ដែលធ្វើឲ្យការងារបង្កបង្កើនផលដំណាំស្រូវសម្រេចបាន៣៣,៨២% លើសឆ្នាំមុន០,៨២% បើប្រៀបធៀបរយៈពេលដូចគ្នា។ ជារួម នៅក្នុងខែមិថុនានេះ ស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៥មានសភាពលឿនជាងឆ្នាំមុនប្រមាណ៧២.៥៤៩ហិកតា។ បច្ចុប្បន្ននេះ ប្រជាកសិករបាននិងកំពុងខិតខំជំរុញការរៀបចំដីភ្ជួររាស់ សាប ព្រោះ និងដកស្ទូង ដើម្បីឲ្យទាន់រដូវកាលដាំដុះ។ ដោយឡែក ចំពោះជំងឺឆ្លងសត្វ និងជំងឺឆ្លងរាតត្បាតផ្សេងៗលើសត្វពាហនៈពុំមានចោទជាបញ្ហាទេ។ ក្រសួងបានចាត់មន្ត្រីជំនាញឲ្យចុះត្រួតពិនិត្យតាមដានជំងឺឆ្លងសត្វផ្សេងៗ ចាក់វ៉ាក់សាំងការពារជាប់ជាប្រចាំ នឹងបន្តចុះទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត។ រីឯលទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗទៀតដែលសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០១៥នេះមានដូចខាងក្រោមៈ

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ លទ្ធផលការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាឆ្នាំ២០១៥

- ផ្ទៃដីភ្ជួររាស់សរុបចំនួន១.១៦១ហិកតា ក្នុងនោះភ្ជួររាស់ដោយគោ ក្របីចំនួន៧៧.៣៣២ហិកតា ស្មើនឹង៦,៦៥% និងគ្រឿងយន្តចំនួន១.០៨៤.៨៧៥ហិកតា ស្មើនឹង៩៣,៣៥% លើសឆ្នាំមុនចំនួន១៥.០៥៧ហិកតា
- ផ្ទៃដីសាបសរុបចំនួន៨.៨៨៣ហិកតា តិចជាងឆ្នាំមុនចំនួន២០.៩៨៨ហិកតា
- ផ្ទៃដីសន្ទូងនិងពង្រោះសម្រេចបានចំនួន៨៦៨.១៧៧ហិកតា ស្មើនឹង៣៣,៨២% នៃផែនការ២.៥៦៧.១៣០ ហិកតា លើសឆ្នាំមុនចំនួន៧២.៥៤៩ហិកតា ក្នុងនោះស្រូវតាមប្រភេទមានៈ
  + ស្រូវស្រាលចំនួន២៥០.៣៩៣ហិកតា ក្នុងនោះ ស្រូវបង្កើនរដូវចំនួន៧៦.១១៨ហិកតា តិចជាងឆ្នាំមុនចំនួន២៩.២៧១ហិកតា
  + ស្រូវកណ្តាលចំនួន៣៣៣.៧៦៧ហិកតា លើសឆ្នាំមុនចំនួន៦៧.៥០០ហិកតា
  + ស្រូវធ្ងន់ចំនួន២២០.៥៧០ហិកតា លើសឆ្នាំមុនចំនួន៤៩.៧៦៩ហិកតា
  + ស្រូវចម្ការចំនួន២០.៨១៥ហិកតា តិចជាងឆ្នាំមុនចំនួន៧.១៧៥ហិកតា
  + ស្រូវឡើងទឹកចំនួន៤២.៦៣២ហិកតា តិចជាងឆ្នាំមុនចំនួន៨.២៧៤ហិកតា។

#### ១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

- ផ្ទៃដីដំណាំរួមផ្សំសម្រេចបានចំនួន៥២៧.៤៣៥ហិកតា ស្មើនឹង៩៤,៥៩% នៃផែនការ៥៥៧.៦១៣ហិកតា តិចជាងឆ្នាំមុនចំនួន១១.៧០០ហិកតា
- ផ្ទៃដីដំណាំឧស្សាហកម្មសម្រេចបានចំនួន៣៩.១១៥ហិកតា ស្មើនឹង៣០,១៥% នៃផែនការ១២៩.៧៤២ហិកតា តិចជាងឆ្នាំមុនចំនួន២៦.២៧២ហិកតា។



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

### ១.៣ ស្ថានភាពនៃការនាំចេញអង្ករក្នុងរយៈពេល៦ខែដើមឆ្នាំ២០១៥

បរិមាណអង្ករនាំចេញមានចំនួន ២៨៣.៨២៥តោន មានការកើនឡើងចំនួន ១០៥.៨៩៧តោន លើស៦ខែដើមឆ្នាំ ២០១៤ ដែលនាំចេញបានតែ ១៧៧.៩២៨តោន។ ដោយឡែកបរិមាណអង្ករនាំចេញក្នុងខែមិថុនា ឆ្នាំ២០១៥នេះ មានរហូតដល់ ៤០.៨០០តោន ដែលមានការកើនចំនួន១១.១៣៤តោន ច្រើនជាងបរិមាណនាំចេញក្នុងខែមិថុនា ឆ្នាំ២០១៤ ដែលនាំចេញបានតែ ២៩.៦៦៦តោន

អង្ករកម្ពុជាបាននាំចេញទៅកាន់ទិសដៅចំនួន៥១ប្រទេស (មានកំណើន៥ប្រទេសធៀបនឹង៥ខែដើមឆ្នាំ២០១៥) ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ (៧២.០៨៦តោន) ប្រទេសបារាំងឈរលំដាប់ទី២ (៣៦.២៣៣តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (៣២.២៦៨តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤ (២៦.៣៨២តោន) ប្រទេសនីឌ័រឡេនឈរលំដាប់ទី៥ (១៨.១៧៩តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៦ (១៣.៣០១តោន) ប្រទេសប៊ែលហ្ស៊ិកឈរលំដាប់ទី៧ (១២.១៧១តោន) សាធារណរដ្ឋឆេកឈរលំដាប់ទី៨ (១០.២៨០តោន) ប្រទេសក្រិចឈរលំដាប់ទី៩ (៨.៨៩១តោន) និង ប្រទេសអង់គ្លេសឈរលំដាប់ទី១០ (៨.០១៥តោន)។ បរិមាណអង្ករដែលនាំចេញទៅកាន់ប្រទេសជាទិសដៅសហគមន៍អឺរ៉ុប២៦ប្រទេស មានបរិមាណសរុប ១៧១.៣៧១តោន (៦០%) ទិសដៅអាស៊ាន៣ប្រទេសមានបរិមាណ ៣០.០២៦តោន (១១%) និងទិសដៅដទៃទៀត២២ប្រទេស មានបរិមាណ៨១.៤២៨តោន (២៩%) ។

## ២ ផ្នែកកៅស៊ូ

### ២.១ ការខារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៤៤,៣១ | ២៦៣,២៩ | ១៩៩,០០ |
| សរុប I | | ៤០៦,៦០ | ៣៤៤,៣១ | ២៦៣,២៩ | ១៩៩,០០ |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១០.៧១៩,០០ | ៤.៤៣៤,០៩ | ១០.១៤៣,៧៩ | ៨.២៤៥,២៨ |
| ២ | ក្រុមហ៊ុន ស៊ីហ្វាប់បើលីមីធីត (រតនគិរី) | ៧៨,៥៣ | ២.០៦៤,៣០ | ១០៧,៩៧ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៨០ | ១.០៨២,១២ | ៤២៩,៤៨ | ២០០,០០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.៦៤៥.៩៧ | ៣.០៦៥,៣៨ | ២.៥២៥,៥៥ | ២.០២១,២០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៥.៣៤៦,៦៩ | ១.៧៨៥,៧៥ | ១.២៤៤,៤០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វីសេសស៍ (ស្នួល) | ១.៧៤៤,៧៨ | ២.៦៤១,៤៣ | ៩២៨,១៣ | ៦៣០,០០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.០២៩,៧០ | ១.២៣៧,៥៩ | ៦៩១,០០ | ៣១១,២០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣.១១១,៦៥ | ១.២១៥,៥៥ | ៧២០,២៦ | ៤៦២,០០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ៨៧៥,៦៦ | - | - |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.៣៩៣,៥៥ | ២.៤៧៥,៣៨ | ២.៤១២,២១ | ១.៨០២.៦០ |
| សរុប II | | ២៨.២៣៣,៧២ | ២៤.៤៣៨,១៩ | ១៩.៧៤៤,១៤ | ១៤.៩១៦,៦៨ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៦.៤១៥,០០ | ១៥៥.២៦២,០០ | ១.៩០៩,២០ | ១.៥៩១,០០ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៧៣.៣៩៦,០០ | ៦៦.៩៥០,០០ | ៣១.៥៧២,០០ | ២៤.២៨៤,០០ |
| សរុប III | | ៧៩.៨១១,០០ | ២២២.២១២,០០ | ៣៣.៤៨១,២០ | ២៥.៨៧៥,០០ |
| សរុប I+II+III | | ១០៨.៤៥១,៣២ | ២៤៦.៩៩៤,៥០ | ៥៣.៤៨៨,៦៣ | ៤០.៩៩០,៦៨ |

- គួរកត់សម្គាល់ថាក្នុងខែមិថុនា ឆ្នាំ២០១៥នេះ តម្លៃកៅស៊ូជាមធ្យមគឺ ១.២១៥,២០ដុល្លារក្នុងមួយតោន។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ធ្វើតេស្តភាគសំណាកយថាប្រភេទបានចំនួន១៣៩ភាគសំណាក ដើម្បីបញ្ជាក់គុណភាពកែច្នៃកៅស៊ូរបស់រោងចក្រក្រុមហ៊ុន ឡុង ស្រេង និងក្រុមហ៊ុន អ៊ឹម តិច
- ធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី១២២ជាមួយ IRA (International Rubber Association)
- ស្រង់និងត្រួតពិនិត្យទិន្នន័យទឹកជ័រគ្រប់ចម្ការពិសោធន៍ និងបញ្ចូលទិន្នន័យចម្ការពិសោធន៍
- សហការជាមួយCIRAD ប្រទេសបារាំង រៀបចំសិក្ខាសាលាស្តីពីការផ្ទេរបច្ចេកវិទ្យាដើម្បីអភិវឌ្ឍន៍កៅស៊ូគ្រួសារនៅកម្ពុជា
- បើកវគ្គបណ្តុះបណ្តាលដល់កសិករចំនួន៤វគ្គគឺៈ១-វគ្គដាំដុះនិងថែទាំកៅស៊ូ ២-វគ្គគ្រប់គ្រងច្បារពូជនិងថ្នាលកូន ៣-វគ្គប្រមូលទឹកជ័រនិងការចៀរជ័រ ៤-វគ្គគ្រប់គ្រងសមាសភាពចម្រៃនិងជំងឺ ដែលមានអ្នកចូលរួមចំនួន២១៣នាក់
- ទទួលជួបពិភាក្សាជាមួយលោកស្រី Lam Soon Jin អ្នកសេដ្ឋកិច្ចរបស់អគ្គលេខាធិការដ្ឋានសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ
- ដាំពង្រីកច្បារពូជនៅប្លុក២១បានចំនួន៤៩ក្លូន សរុបចំនួន៦.០០០ដើម
- បញ្ជូនមន្ត្រីជំនាញចំនួន៦រូបទៅចូលរួមក្នុងកិច្ចប្រជុំនិងសិក្ខាសាលានៅប្រទេសម៉ាឡេស៊ី និងប្រទេសថៃ
- ដឹកនាំនិស្សិតសរសេរសារណាបទថ្នាក់បរិញ្ញាបត្របានចំនួន១៥នាក់ មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យស្វាយរៀង និងសាលាជាតិកសិកម្មកំពង់ចាម។

## ៣ ផ្នែកផលិតកម្មនិងបសុពេទ្យ

### ៣.១ ការងារវិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ

- ជ្រូកសរុបចំនួន២៤០ក្បាល នៅក្នុងស្ថានីយពិសោធន៍ពូជជ្រូក ក្នុងនោះជ្រូកបាចំនួន៩ក្បាល ជ្រូកមេចំនួន៨៨ក្បាល និងកូនជ្រូកចំនួន១៤៣ក្បាល
- គោសរុបចំនួន១៥៨ក្បាល នៅក្នុងស្ថានីយចិញ្ចឹមគោ ក្នុងនោះគោបាចំនួន៣ក្បាល គោប្រាម៉ាន់កាត់ចំនួន៣៥ក្បាល គោជំទង់ចំនួន៣៤ក្បាល គោបៅដោះចំនួន៤៤ក្បាល និងគោកំផែងសែនចំនួន៤២ក្បាល
- វិទ្យាស្ថានបានខិតខំពង្រឹងសកម្មភាពពិសោធន៍ស្រាវជ្រាវដូចខាងក្រោមៈ
  + លើកគម្រោងលក់កូនជ្រូកគ្រប់អាយុដែលត្រូវលក់និងមេបាជម្រុះ
  + កែច្នៃទឹកមេជីវិតនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅ
  + រៀបចំសកម្មភាពគម្រោងគាំទ្រដោយសហភាពអឺរ៉ុបទាក់ទងនឹងការងារកែច្នៃទឹកមេជីវិតគោ
  + លើកសំណើទៅភាគីចិនដើម្បីបង្កើតមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិតគោ មន្ទីរពិសោធន៍វិភាគចំណីសត្វ មន្ទីរពិសោធន៍សេនេទិច និងមន្ទីរពិសោធន៍កាកសំណល់ថ្នាំ
  + រៀបចំស្នើសុំទិញឧបករណ៍វិភាគចំណីតាមរយៈគម្រោងសហភាពអឺរ៉ុបនិងគម្រោងអនាម័យ និងភូតគាមអនាម័យ (SPS)។

### ៣.២ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

- ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី ជំងឺសារទឹកចំនួន៤៦៨.៤៧៤ក្បាល ជំងឺអុតក្តាមចំនួន១០.១៤៩ក្បាល និងជំងឺបូសខ្យល់ចំនួន៣.៦៣៤ក្បាល
- ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន៦០.១៦៧ក្បាល ជំងឺប៉េស្តចំនួន១០៨.២០៥ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន៦៤.៦៧៤ក្បាល ជំងឺអុតក្តាមចំនួន៧.៩១៩ក្បាល ជំងឺអូហ្យេស្គីចំនួន១៨.១១៥ក្បាល ជំងឺកញ្ជ្រឹលចំនួន៤.១៤៥ក្បាល ជំងឺជាតិដែកចំនួន១២.០២៥ក្បាល ជំងឺរាគកូនជ្រូកចំនួន១៣.៥៧៥ក្បាល ជំងឺផ្លូវដង្ហើមចំនួន៥.៦៦៥ក្បាល
- ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន៣២៨.៥៦៩ក្បាល ជំងឺញ៉ូវកាសចំនួន៥៥៤.០៤២ក្បាល ជំងឺអាសន្នរោគចំនួន៤៣៨.៥១៥ក្បាល ជំងឺហ្គុមបូរ៉ូចំនួន១.៧៥២ក្បាល និងជំងឺប៉េស្តទាចំនួន៣៤៣.៩៤១ក្បាល។

### ៣.៣ ការងារឡជីវឧស្ម័ន

ដោយមានការអភិវឌ្ឍន៍វិស័យចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់តាមរយៈការអប់រំ ណែនាំ ផ្សព្វផ្សាយការអនុវត្តល្អប្រសើរការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅ

តាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននឹងកំពុងអនុវត្តយ៉ាងសកម្មដែលមកទល់ពេលនេះ ខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិសាត់សម្រេចបាន៨៨២ឡ (របាយការណ៍ខែឧសភាឆ្នាំ២០១៥) និងឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបាន១២០ឡ (គិតត្រឹមថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤) សរុបរួម: ១.០០២ឡ។

### ៣.៤ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

- ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម សារទឹក បូសខ្យល់ និងជំងឺប៉េស្តជ្រូក
- រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ
- អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅតាមខេត្ត-រាជធានី
- បានពិនិត្យវត្ថុវិភាគសរុបចំនួន២.៥១៩សំណាក
- ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន និងផលិតឡជីវឧស្ម័នសរុបចំនួន១.០០២ឡ។

### ៣.៤ ការអនុវត្តវិធានបសុពេទ្យ

- បានទទួលព័ត៌មានទាន់ហេតុការណ៍នូវទូរស័ព្ទហៅចូលចំនួន៦មកពីខេត្តសៀមរាប កំពង់ចាម កំពង់ស្ពឺ និងខេត្តកណ្តាល សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព រាយការណ៍ពីបក្សីឈឺ ងាប់ និងវិធានការការពារជំងឺផ្តាសាយបក្សី

- ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោចំនួន២៨១លើក ក្របីចំនួន៦៥លើក ជ្រូកចំនួន៧៨១លើក មាន់ចំនួន២.៧៦១លើក ទាចំនួន៣៧.៧៩៤លើក កន្លែងពិឃាតមាន់ចំនួន១៧៤លើក កន្លែងលក់មាន់ចំនួន១៨១លើក ទ្រុងចិញ្ចឹមចំនួន១.៧៣៤លើក បរិវេណភូមិចំនួន១៤១លើក សត្តឃាតដ្ឋានចំនួន៤០៣លើក តាមផ្លូវជាតិចំនួន៣៥លើក និងកន្លែងផ្ទុះជំងឺចំនួន១៦លើក

- ក្រុមអន្តរាគមន៍របស់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាលសហការជាមួយមន្ទីរកសិកម្មរាជធានី-ខេត្ត បានបន្តចុះត្រួតពិនិត្យនិងបង្ក្រាបបទល្មើសចលនាដឹកជញ្ជូនសត្វនិងផលិតផលមានដើមកំណើតពីសត្វជាប់ជាប្រចាំ ជាពិសេសបណ្តាខេត្តនៅជាប់ព្រំដែន។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

- ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង កំពង់ធំ និងសៀមរាប) ដែលមានសត្វស្លាបប្រមាណ១៩២ប្រភេទ (ប្រហែល១១២.៨០៩ក្បាល)

- ផ្តល់ចំណីដល់សត្វត្មាតនៅព្រៃការពារខេត្តព្រះវិហារ សៀមប៉ាងខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ដោយរាប់ឃើញសត្វត្មាតសរុបចំនួនប្រមាណ២៥៣ក្បាល

- ការពារសម្បុកសត្វត្រដក់តូចចំនួន៥៣ សត្វត្រយ៉ងចង្កំ ក ស ចំនួន៥២ ត្មាតចំនួន៦ ត្រយ៉ងយក្សចំនួន៥ និងរំពេរទន្លេចំនួន១៨ នៅសៀមប៉ាង ខេត្តស្ទឹងត្រែង ខេត្តក្រចេះ និងខេត្តព្រះវិហារ។

### ៤.២ ការងារសហគមន៍ព្រៃឈើ

- ធ្វើការអប់រំផ្សព្វផ្សាយពីសារសំខាន់នៃការអភិរក្សសត្វព្រៃ ពង្រឹងការអនុវត្តច្បាប់ រៀបចំផែនការយុទ្ធសាស្រ្តទប់ស្កាត់ ការកាប់ឈើ កាប់រានដីព្រៃ និងការអភិរក្សជីវចម្រុះ ការកំណត់ព្រំប្រទល់តំបន់ប្រើប្រាស់ដីធ្លី ផ្លាស់ប្តូរបទពិសោធន៍ អំពីការចិញ្ចឹមឃ្មុំប្រកបដោយនិរន្តរភាព និងពង្រឹងសមត្ថភាពសហគមន៍ក្នុងការការពារ និងអភិរក្សធនធានធម្មជាតិ ដោយមានអ្នកចូលរួមសរុបចំនួន៥.៦៣៨នាក់ ក្នុងនោះស្ត្រី១.៣៨៤នាក់

- ធ្វើការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និងអាជ្ញាធរខេត្តមណ្ឌលគិរី ដើម្បីពិភាក្សាអំពីផែនការគ្រប់គ្រងតំបន់ព្រៃការពារមណ្ឌលគិរី ព្រៃឡង់ក្នុងខេត្តកំពង់ធំ សៀមប៉ាងខេត្តស្ទឹងត្រែងចំនួន២លើក

- បិទប្រកាសជាសាធារណៈជាលើកទី២នូវផែនទីស្តីពីលទ្ធផលនៃការប្រមូលទិន្នន័យស្តីពីការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋភូមិដងផ្លិត រួមមានដីកសិកម្មនិងដីលំនៅដ្ឋាន ដើម្បីឱ្យប្រជាពលរដ្ឋធ្វើការត្រួតពិនិត្យ និងកែសម្រួលក្បាលដីដែលមានបញ្ហាសរុបចំនួន៦៣១ក្បាលដី ស្មើនិង៦៨៥,៧៥ហិកតា ក្នុងនោះ ដីកសិកម្មមានចំនួន៤០៥ក្បាលដី ស្មើនិង៦៥២,៨៦ហិកតា និងដីលំនៅដ្ឋានមានចំនួន២២៦ក្បាលដី ស្មើនិង៣២.៨៩ហិកតា

- បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងគ្រប់គ្រងតំបន់ព្រៃសហគមន៍ស្ថិតនៅក្នុងខេត្ត០៣ ក្នុងនោះរួមមានខេត្តបាត់ដំបងមានចំនួន៦សហគមន៍ព្រៃឈើ ស្មើនឹង២៦កន្លែង មានផ្ទៃដីសរុបទំហំ៧៨៦ហិកតា ខេត្តស្ទឹងត្រែងមានចំនួន២សហគមន៍ព្រៃឈើ ស្មើនឹង២កន្លែង មានផ្ទៃដីសរុបទំហំ៧៦៤ហិកតា និងខេត្តពោធិ៍សាត់ដែលមានចំនួន២៥សហគមន៍ព្រៃឈើ ស្មើនឹង២៦កន្លែង មានផ្ទៃដីសរុបទំហំ៦.៦៥៥ហិកតា

- ចេញប្រកាសស្តីពីការបង្កើត និងគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន០៤សហគមន៍ព្រៃឈើ ក្នុងនោះរួមមានខេត្តស្វាយរៀងមាន០២សហគមន៍ព្រៃឈើ គ្របដណ្តប់លើផ្ទៃដីសរុបទំហំ៣៦ហិកតា និងខេត្តបាត់ដំបងមាន០២សហគមន៍ព្រៃឈើ គ្របដណ្តប់លើផ្ទៃដីសរុបទំហំ៥៧៩ហិកតា

- ចុះកិច្ចព្រមព្រៀងព្រៃសហគមន៍រវាងខណ្ឌរដ្ឋបាលព្រៃឈើ និងប្រធានគណៈកម្មការសហគមន៍ព្រៃឈើ បានចំនួន១៩សហគមន៍ព្រៃឈើគ្របដណ្តប់លើផ្ទៃដីសរុបទំហំ២០.៦០៧ហិកតា នៅក្នុងខេត្តចំនួន៤ក្នុងនោះ ខេត្តបាត់ដំបងចំនួន០២សហគមន៍ព្រៃឈើ គ្របដណ្តប់លើផ្ទៃដីសរុបទំហំ៥៧៩ហិកតា ខេត្តក្រចេះចំនួន១០សហគមន៍ព្រៃឈើគ្របដណ្តប់លើផ្ទៃដីសរុបទំហំ១៧.៧៩៥ហិកតា ខេត្តកំពង់ធំចំនួន០៣សហគមន៍ព្រៃឈើគ្របដណ្តប់លើផ្ទៃដីសរុបទំហំ៧៥០ហិកតា និងខេត្តរតនគិរីចំនួន០៤សហគមន៍ព្រៃឈើគ្របដណ្តប់លើផ្ទៃដីសរុបទំហំ១.៤៨៣ហិកតា

- មានភ្ញៀវទេសចរបរទេសចំនួន១.១៥៧នាក់ មកទស្សនាសត្វទោចក្នុងតំបន់អភិរក្សជីវចម្រុះវ៉ុនសៃ-សៀមប៉ាង អាងត្រពាំងថ្ម សីម៉ា ព្រះវិហារ កំពង់ធំ និងសៀមរាប ដោយបានផ្តល់ប្រាក់ចំណូលបន្ថែមដល់សហគមន៍មូលដ្ឋាន

- បន្តសហការជាមួយអង្គការ CSIRO នៃប្រទេសអូស្ត្រាលី ដោយផ្តល់ពូជ បច្ចេកទេស បង្កើតចម្ការពូជឈើអាកាស្យាម៉ង់ស្យូមទំហំ០៥ហិកតា នៅស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើក្បាលឆាយ

- បន្តការចុះស្រាវជ្រាវអំពីសត្វល្អិត Leptocybe invasa នៅក្នុងស្ថានីយដាំឈើចំនួន៣ទីតាំង (មានក ស្ទួលទ្រេត ក្រសាំង) និងក្រុមហ៊ុន Kamarkara។ ជាលទ្ធផលនៃការស្រាវជ្រាវបានរកឃើញនិងប្រមូលសំណាកនៃសត្វល្អិត Leptocybe invasa ដោយបានធ្វើការវិភាគទិន្នន័យ និងពិភាក្សាជាមួយក្រុមការងារនៃគម្រោងក្នុងប្រទេសចំនួន៤។

### ៤.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជសត្វក្តាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ឆមាសទី១ ឆ្នាំ២០១៥នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹមនិងថែរក្សា៖ សត្វចំណូលថ្មីចំនួន៨០៧ក្បាល សត្វកើតថ្មីចំនួន៤៧ក្បាល សត្វដោះលែងចំនួន៨១៥ក្បាល សត្វស្លាប់ចំនួន៤០ក្បាល ព្យាបាលសត្វចំនួន១.២៦៩ក្បាល យកសំណាកទៅពិសោធន៍ចំនួន២៩២ក្បាល ធ្វើឲ្យសន្លប់ចំនួន៧៤ក្បាល ទម្លាក់សត្វល្អិតចំនួន៣៤៩ក្បាល វះកាត់សាកសពសត្វចំនួន៣២ក្បាល ដាក់លេខកូដចំនួន៤ក្បាល ចាក់វ៉ាក់សាំងចំនួន៤០ក្បាល សាងសង់ទ្រុងសត្វថ្មីលើផ្ទៃដីចំនួន១.១២៨,២ម$^2$ ជួសជុលទ្រុងសត្វនិងអគារផ្សេងៗចំនួន៤១៤ម$^2$ ជួសជុលផ្លូវចំនួន៤៥.០០០ម$^2$ សង់បង្គោលភ្លើងចំនួន៥ដើម តបណ្តាញភ្លើងចំនួន៣០០ម ស្តារអនាម័យព្រៃចំនួន៨៧.៦០០ម$^2$ ដាំកូនឈើចំនួន៨៣០ដើម បណ្តុះផ្កាលម្អចំនួន៣៣៧ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន៣.២៧៣នាក់

- ក្រុមហ៊ុនចំនួន៦ គ្រប់គ្រងកសិដ្ឋានចំនួន៧ កំពុងចិញ្ចឹមសត្វក្តាមចំនួន៥៥.១៩៥ក្បាល និងបាននាំចេញចំនួន១.៩៤៧ក្បាល។

### ៤.៤ ការងារដាំដើមឈើ

- ទីតាំងរុក្ខទិវាថ្នាក់ជាតិសម្រាប់ឆ្នាំ២០១៥នេះត្រូវបានជ្រើសរើសនៅតំបន់ថ្មសំលៀង ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ និងកំពុងរៀបចំទីតាំងប្រារព្ធពិធីសាងសង់វេទិកា និងត្រៀមកូនឈើសម្រាប់ដាំ

- ការដាំឈើក្នុងចម្ការព្រៃឈើដាំបានឈូសឆាយដីសម្រាប់ឆ្នាំ២០១៥សរុបចំនួន៤.៦៨៥ហិកតា និងដាំឈើជាចម្ការបានចំនួន១១០ហិកតា

- តាមដានព័ត៌មានភ្លើងឆេះព្រៃតាមរយៈផ្កាយរណបរបស់អង្គការ NASA ដោយប្រព័ន្ធ INTERNET និងបញ្ជូនព័ត៌មានទៅតាមខណ្ឌរដ្ឋបាលព្រៃឈើដើម្បីមានវិធានការទប់ស្កាត់ និងពន្លត់ភ្លើងព្រៃ។

### ៤.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញឈើកែច្នៃជូនក្រុមហ៊ុនចំនួន៤ ដែលមានបរិមាណឈើកែច្នៃគ្រប់ប្រភេទចំនួន៧.៣៣១ម$^3$ ដើមចន្ទន៍ក្រស្នា(រុក្ខជាតិរស់)ចំនួន៧២ដើម

- បន្តអភិរក្សលើដំណាំចំនួន៣១ប្រភេទ ដែលក្នុងនោះរួមមាន ស្រូវចំនួន៦.៩៧៨បញ្ជីក/សំណាក ស្រូវវ៉ៃចំនួន ២៩១បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន២៩ប្រភេទមាន៧១១បញ្ជីក/សំណាក

- ដឹកនាំនិស្សិតស្រាវជ្រាវនិងសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របានចំនួន០៩នាក់ មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម

- បើកវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា និងសន្និបាតចំនួន០៦លើក ដែលមានអ្នកចូលរួមសរុបចំនួន២៨៧នាក់

- ចូលរួមវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា និងសន្និបាតក្នុងប្រទេសចំនួន៣៩លើក ដែលមានមន្ត្រីចូលរួមចំនួន ៣៩នាក់ និងក្រៅប្រទេសចំនួន២១លើក ដែលមានអ្នកចូលរួមចំនួន២៦នាក់ និងមន្ត្រីសរុបចំនួន៣រូប បានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតនៅក្រៅប្រទេស

- ការស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មក្នុងគេហទំព័រ www.cardi.org.kh និង www.crkb.org.kh មានអ្នកចូលរួមសរុបចំនួន១៦១.១៣០នាក់ គិតជាមធ្យមប្រមាណ១.០៧៤នាក់ក្នុងមួយថ្ងៃ

- ធ្វើទិវាស្រែបង្ហាញនិងវាយតម្លៃចំនួន០៦កន្លែងនៅខេត្តតាកែវ ខេត្តស្វាយរៀង និងខេត្តកំពត ដែលមានកសិករចូលរួមសរុបចំនួន៥៣៦នាក់។

## ៧ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា សរុបចំនួន២.៧២៧ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទសរុបចំនួន ១.៨១៩ច្បាប់ ទទួលពីរាជធានី ខេត្ត សរុបចំនួន៦៣៤ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត សរុបចំនួន៤.២៨៨ច្បាប់ ប្រកាស សេចក្ដីសម្រេច និងសារាចរ សរុបចំនួន៣២០ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ សរុបចំនួន១៥៤ច្បាប់

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ។ល។

## ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៧៨៧នាក់ នារីចំនួន១.៣៥៨នាក់ ស្មើនឹង២០%រួមមាន៖
  - + អង្គភាពថ្នាក់កណ្ដាលចំនួន៤.១៣០នាក់ ក្នុងនោះនារីចំនួន៧៨២នាក់ ស្មើនឹង១៩%
  - + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦៥៧នាក់ ក្នុងនោះនារីចំនួន៥៧៦នាក់ ស្មើនឹង២២%

- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន៥៨នាក់ ក្នុងនោះបោះបង់ការងារចំនួន២០នាក់ សុំលាឈប់ពីការងារចំនួន២៥នាក់ និងមរណភាពចំនួន១៣នាក់

- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន០៦នាក់ ផ្ទេរចូលក្រសួងចំនួន០៤នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន៥៦នាក់

- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្ដាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

- ត្រៀមរៀបចំបែបបទសម្រាប់ការប្រឡងជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការឆ្នាំ២០១៥។

## ៩ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បញ្ជូនមន្ត្រីចំនួន៥រូបចូលរួមបើកវគ្គបណ្ដុះបណ្ដាលកសិករលើប្រធានបទស្ដីពី និរន្តរភាពនៃផលិតកម្មដំឡូងមីសម្រាប់កសិករខ្នាតតូច នៅខេត្តកំពង់ចាម ខេត្តប៉ៃលិន និងខេត្តបាត់ដំបង

- បញ្ជូនមន្ត្រីចំនួន១៨០រូបចូលរួមសិក្ខាសាលាស្ដីពី វិស័យកសិកម្មកម្ពុជា ការត្រៀមជាសម្រេចសម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ាន និងតទៅអនាគតក្នុងប្រទេស

- បញ្ជូនមន្ត្រីចំនួន៧៨រូប ចូលរួមសិក្ខាសាលាស្ដីពីកម្រិតកាកសំណល់ជាតិពុល និងកិច្ចប្រជុំលើកទី១៩ នៃក្រុមការងារជំនាញស្ដីពីការធ្វើសុខដុមនីយកម្មកម្រិតកាកសំណល់ជាតិពុលនៃថ្នាំពុលកសិកម្ម កិច្ចប្រជុំលើកទី៦ របស់ក្រុមការងារជំនាញស្ដីពីការអនុវត្តកសិកម្មល្អ កិច្ចប្រជុំថ្នាក់តំបន់និងអន្តរជាតិរបស់ក្រុមការងារបច្ចេកទេសក្រពើ និងកិច្ចប្រជុំរបស់មជ្ឈមណ្ឌលអាស៊ានសម្រាប់ក្រុមប្រឹក្សាអភិវឌ្ឍន៍សហគមន៍កសិកម្មលើកទី២២ កិច្ចប្រជុំលើកទៅ១៧ របស់ក្រុមការងារអាស៊ានស្ដីពីសហគមន៍កសិកម្ម នៅខេត្តសៀមរាប

- បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាសរុបចំនួន១៩៩រូប នៅប្រទេសចំនួន២៤

- រៀបចំលិខិតអន្តរាគមន៍ទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំលិខិតឆ្លងដែនចំនួន ១៥ច្បាប់ ជូនមន្ត្រីរាជនិងពន្យារទិដ្ឋាការស្នាក់នៅជូនក្រុមអ្នកបច្ចេកទេសចិនចំនួន២៣រូប

- រៀបចំលិខិតទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោងអាទិភាព៥ឆ្នាំ វ័កិលឆ្នាំ ២០១៥-២០១៩ ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការហិរញ្ញប្បទានពីសាធារណរដ្ឋប្រជាមានិតចិន ព្រមទាំងកិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយដៃគូពាក់ព័ន្ធផ្សេងៗទៀតរួមទាំងអង្គការជាតិ និងអន្តរជាតិផងដែរ

- បានរៀបចំទិវាពិភពលោកប្រយុទ្ធប្រឆាំងនិងរហោស្ថានកម្ម ឬឱនភាពដីឆ្នាំ២០១៥ នៅឃុំរស្មីសាមគ្គី ស្រុកឱរាល់ ខេត្តកំពង់ស្ពឺក្រោមប្រធានបទ " គ្មានផលណាល្អដែលកើតឡើងឯកឯងឡើយ -យើងត្រូវខំប្រឹងប្រែងនិងចំណាយដើម្បីធ្វើឱ្យដីល្អ " ដែលមានមន្ត្រីរាជការ និស្សិត ប្រជាកសិករចូលរួមជាង៦០០នាក់

## ១០ ការខារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបចំនួន១.២២៣នាក់(ស្រី៣៩៦នាក់) ក្នុងនោះនិស្សិតបរិញ្ញាចំនួន១.០១៥នាក់(ស្រី៣៤៦នាក់) និងនិស្សិតបរិញ្ញារងចំនួន២០៨នាក់(ស្រី៤៦នាក់) ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។ សហការជាមួយក្រសួងអប់រំយុវជននិងកីឡាក្នុងការកែលម្អកម្មវិធីសិក្សាក្នុងគោលបំណង ប្រែក្លាយសាលាជាតិកសិកម្មព្រែកលៀបទៅជាសាកលវិទ្យាល័យជាតិព្រែកលៀប។ សាលាជាតិបាននឹងកំពុងបំពាក់ប្រព័ន្ធអ៊ីនធ័រណែត និងដំឡើងស៍រវ័រ(Sever) ព្រមទាំងបន្តសហការយ៉ាងជិតស្និទ្ធជាមួយភាគីចិនកំពុងសាងសង់មន្ទីរពិសោធន៍ដែលគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០១៥នេះ។

### ១០.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបមានចំនួន១.២១៨នាក់(ស្រី៤៥៨នាក់) រួមមាន៖

- និស្សិតអាហារូបករណ៍សរុប៨៤៨នាក់ (ស្រី៣៤១នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៦៩០នាក់ (ស្រី២៤១នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម១៥៨នាក់(ស្រី១០០នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃ២២៨នាក់ (ស្រី៦៧នាក់) ថ្នាក់បរិញ្ញាចំនួន២១៧នាក់(ស្រី៦៦នាក់) និងថ្នាក់បរិញ្ញារងចំនួន១១នាក់ (ស្រី១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។ សាលាជាតិបានលើកគម្រោងចំនួន១១គម្រោងស្នើសុំថវិកាសម្រាប់ធ្វើការស្រាវជ្រាវលើប្រធានបទការពិសោធន៍កសិកម្ម វារីវប្បកម្ម បសុវប្បកម្ម និងសង្គមជនបទ។

### ១០.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតកំពុងសិក្សាមានចំនួនសរុប៥.៩៧៧នាក់(ស្រី១.៤០០នាក់) ចែកចេញជា១០មហាវិទ្យាល័យ គឺមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមបានបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ សាកលវិទ្យាល័យបានរៀបចំសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធស្តីពីការអភិវឌ្ឍកម្មវិធីសិក្សារបស់មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ និងកសិ-ឧស្សាហកម្ម ក្រោមជំនួយរបស់គម្រោងSPS និងបានពិភាក្សាជាមួយក្រុមការងារក្រសួងអភិវឌ្ឍន៍ជនបទ និងភាគីកូរ៉េ ក្នុងការត្រៀមរៀបចំបង្កើតនិងបញ្ចូលកម្មវិធីសិក្សាចលនាភូមិថ្មី។ សាកលវិទ្យាល័យបានទទួលបដិសណ្ឋារកិច្ចនិងប្រជុំពិភាក្សាជាមួយគណៈប្រតិភូរដ្ឋសភានិងឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឆេក ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការលើការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យកសិកម្មកម្ពុជា និងទទួលជួបពិភាក្សាជាមួយឯកអគ្គរដ្ឋទូតប្រទេសអ៊ីស្រាអែល ស្តីពីការបន្តកិច្ចសហការបញ្ជូននិស្សិតទៅចូលរួមធ្វើកម្មសិក្សានៅប្រទេសអ៊ីស្រាអែល រយៈពេល១១ខែ សរុបចំនួន១០២នាក់ជារៀងរាល់ឆ្នាំ។

បានបើកវគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃគម្រោង វគ្គពង្រឹងសមត្ថភាពស្តីពី e-Library និង Scientific visibility និងវគ្គស្តីពីប្រព័ន្ធស្នប់បូមទឹក ដោយសហការជាមួយដៃគូអន្តរជាតិដូចជា សាកលវិទ្យាល័យរដ្ឋមីស៊ីហ្គែន សហរដ្ឋអាមេរិក ក្រុមហ៊ុន EBARA ជប៉ុន និងដៃគូដទៃទៀត។ កំពុងបន្តអនុវត្តគម្រោងអភិវឌ្ឍន៍ជនបទ និងគម្រោងស្រាវជ្រាវមួយចំនួន ជាពិសេសគម្រោង ERECON និងគម្រោង SPS, គម្រោងធនាគារពិភពលោកតាមរយៈក្រសួងអប់រំ យុវជន និងកីឡា និងបានបង្កើតគម្រោងថ្មី ស្តីពីការផ្សព្វផ្សាយការចិញ្ចឹមមាន់សាច់ នៅក្នុងខេត្តកណ្តាល និងខេត្តតាកែវ ដោយសហការជាមួយទីភ្នាក់ងារកូរ៉េ KOPIA។ បានបញ្ជូនមន្ត្រីនិងសាស្ត្រាចារ្យទៅបណ្តុះបណ្តាលបច្ចេកទេសបន្ថែមរយៈពេលខ្លីនៅតាមសាកលវិទ្យាល័យដៃគូនានានៅក្នុងប្រទេសហ្វីលីពីន ចិន ថៃ ឥណ្ឌូនេស៊ី និងជប៉ុន។

ជារួមគ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើ តែងតែបញ្ជូននិស្សិតឲ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញ នៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដូចខែមុនៗដែរដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការបង្ហាត់ឲ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិ-ពាណិជ្ជកម្ម រួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូឲ្យកាន់តែទូលំទូលាយ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ក្នុងឆមាសទី១ ឆ្នាំ២០១៥នេះ ស្ថានភាពទឹកភ្លៀងនៅមិនទាន់ធ្លាក់រាយប៉ាយគ្រប់តំបន់ទូទាំងប្រទេសនៅឡើយ តែការងារបង្កបង្កើនផលដំណាំស្រូវសម្រេចបាន៣៣,៨២% លើសឆ្នាំមុន០,៨២% បើប្រៀបធៀបរយៈពេលដូចគ្នា។ ជារួម នៅក្នុងខែមិថុនានេះ ស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៥មានសភាពលឿនជាងឆ្នាំមុន ប្រមាណ៧២.៥៤៩ហិកតា។ បច្ចុប្បន្ននេះ ប្រជាកសិករបាននិងកំពុងខិតខំជំរុញការរៀបចំដីភ្ជួររាស់ សាប ព្រោះ និងដកស្ទូង ដើម្បីឲ្យទាន់រដូវកាលដាំដុះ។ ដំណាំឧស្សាហកម្ម ដំណាំឈើហូបផ្លែនិងដំណាំអចិន្ត្រៃយ៍ កំពុងមានការរីកចម្រើនជាបន្តបន្ទាប់ ជាលក្ខណៈគ្រួសារនិងជាលក្ខណៈវិនិយោគខ្នាតតូច មធ្យម និងធំ។ ជាក់ស្តែង ផ្ទៃដីកៅស៊ូមានសន្ទុះកើនឡើង ពិសេសការអភិវឌ្ឍកៅស៊ូគ្រួសារ មានការវិវឌ្ឍតាមសន្ទុះមួយគួរឱ្យចាប់អារម្មណ៍។ ចំពោះជំងឺឆ្លងសត្វ និងជំងឺឆ្លងរាតត្បាតផ្សេងៗលើសត្វពាហនៈពុំមានចោទជាបញ្ហាទេ។ ក្រសួងបានចាត់មន្ត្រីជំនាញឲ្យចុះត្រួតពិនិត្យតាមដានជំងឺឆ្លងសត្វផ្សេងៗ ចាក់វ៉ាក់សាំងការពារជាប់ជាប្រចាំ នឹងបន្តចុះទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត។

ដោយឡែក ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល កំពុងស្ថិតនៅតែជាប្រធានបទអាទិភាព ហើយដែលអង្គភាពជំនាញជាសេនាធិការនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញការចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែងដើម្បីលុបបំបាត់បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាពក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់។ លើសពីនេះទៅទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវខ្ពស់ទាំងនៅថ្នាក់កណ្តាល និងមន្ទីរកសិកម្មរាជធានី-ខេត្តដោយសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនិមួយៗបានល្អប្រសើរដោយតម្រង់ចក្ខុវិស័យតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៥ ក្នុងវិស័យកសិកម្ម និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។

## IV- ទិសដៅអនុវត្តបន្ត

### ១.ផ្នែកដាំដុះ :

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗនិងការជំរុញការងារបង្កបង្កើនផលដើមរដូវវស្សានេះឲ្យបានទាន់រដូវកាលដាំដុះ

- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអគុល្យភាពស្បៀង (អង្ករ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឲ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារនានាសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសទៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តស្រាវជ្រាវការដាំដុះសាកល្បងក្លូនកៅស៊ូប្រភេទ "Invitro" និងបន្តផ្សព្វផ្សាយអំពីបច្ចេកទេសដ៏មានសារសំខាន់នេះក្នុងក្របខណ្ឌនៃគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា។

**២.ផ្នែកផលិតកម្មនិងបសុពេទ្យាបាល** :

- ចាត់វិធានការដោយសហការជាមួយស្ថាប័ន អាជ្ញាធរមូលដ្ឋាន រួមទាំងភ្នាក់ងារពេទ្យសត្វភូមិ ដើម្បីចុះពិនិត្យនិងតាមដានជាបន្តលើសភាពការណ៍ជំងឺសត្វ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី-ខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ ទន្ទឹមនឹងនោះ ត្រូវធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឲ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឲ្យបានទូលំទូលាយ

- ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី H5N1 និងជំងឺផ្តាសាយ H7N9

- ពង្រឹងត្រួតពិនិត្យចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារអន្តរជាតិ ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឲ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

**៣.ផ្នែកព្រៃឈើ** :

- បន្តជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឲ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក និងការត្រៀមលក្ខណៈដើម្បីរៀបចំពិធីបុណ្យរុក្ខទិវា នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៥ នៅឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធ-សាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២។

### ៤.ផ្នែកជលផល :

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ជំរុញពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៥ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

### ៥.ផ្នែកពាក់ព័ន្ធផ្សេងៗ :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្តាខេត្ត រាជធានី។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មខេត្ត រាជធានី ដោយតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញនៅឆ្នាំ២០១៥ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឲ្យមានប្រសិទ្ធភាព និងការបន្តរៀបចំផែនការថវិកាសម្រាប់ឆ្នាំ២០១៦

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឲ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ។ ទន្ទឹមនឹងនេះ ក៏គិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្ដាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្ដែង

- ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា និងយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យនិងចាត់វិធានការសមស្របដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីរាជការឲ្យបានហ្មត់ចត់

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត អត្ថបទក្រោមច្បាប់ ផែនការយុទ្ធសាស្ត្រ ស្តង់ដារ និងគោលការណ៍ព្រមទាំងពង្រឹងសមត្ថភាពធនធានមនុស្ស និងកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទដើម្បីលើកកម្ពស់វិស័យកសិកម្មនៅកម្ពុជាក្នុងការត្រៀមលក្ខណៈសម្រាប់ការចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំ២០១៥ និងនាពេលអនាគត។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

បណ្ឌិត វ៉េង សាខុន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលឈើអារឈើឡាំង(Chanfuta) ជូនក្រុមហ៊ុនចំនួន០១ ដែលមានបរិមាណឈើចំនួន៨០០ម $^{៣}$ ។

### ៤.៦ ការងារចំណូលព្រៃឈើ

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុនចំនួន៤០ និងអតិថិជនចំនួន៥នាក់ ដែលមានឈើហ៊ុបមូលសរុបចំនួន៥២.៤៧៨ម $^{៣}$ កូនឈើចំនួន៤៨៩.០២៤ដើម អុសចម្រុះចំនួន៩៦.៩២៩ស្ទែរ ជ័រទឹកចំនួន៥១១តោន ផ្តៅចំនួន៣០តោន និងឫស្សីចំនួន៦២៧តោន

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើសម្រាប់នាំចេញជូនក្រុមហ៊ុនចំនួន៥ ស្មើនឹង៥៥សន្លឹក ដែលមានបរិមាណឈើកែច្នៃគ្រប់ប្រភេទចំនួន៦.២៧៣ម $^{៣}$ កម្ទេចឈើចំនួន៨៩៩តោន និងដើមចន្ទន៍ក្រស្នាចំនួន២៥ដើម

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើសម្រាប់នាំចូលជូនក្រុមហ៊ុនចំនួន១ ស្មើនឹង០៥សន្លឹក ដែលមានបរិមាណឈើកែច្នៃគ្រប់ប្រភេទចំនួន១៥៩ម $^{៣}$

- ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន១០.៦៣៨.៥៣១.០៨៩រៀល និងចំណូលពីសេវាសាធារណៈចំនួន៤.១៥៨.៣៣៦.៣៥៦រៀល និង១២៩.៨៥៣,៧៩ដុល្លារ។

### ៤.៧ ការងារនីតិកម្មនិងវិវាទ

- ក្នុងឆមាសទី១ ឆ្នាំ២០១៥នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃ នៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន១.០៦៤ករណី ដោយបញ្ជូនទៅតុលាការចំនួន៧៩១ករណី និងពិន័យអន្តរការណ៍ចំនួន២៧៣ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៣៨១ម $^{៣}$ ឈើអារចំនួន២.៦៨៥ម $^{៣}$ ឈើក្រាក់គ្រញូងចំនួន៧៣ម $^{៣}$ និង៣.០៨២គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន៣.៣៥០ក្បាលនិង១.១៨៣គ.ក្រ និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន១.២០៥ហិកតាត្រូវបានបញ្ជូនសំណុំរឿងទៅតុលាការ និងដកហូតរណារយន្តចំនួន១៦៥គ្រឿង

- បាននិងដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ(Case Tracking System-CTS) ដើម្បីរៀបចំឲ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ធ្វើការឆ្លើយតបរហ័សលើព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើដែលមានចុះផ្សាយក្នុងសារព័ត៌មាននានាសរុបចំនួន៦៨៧ករណី។ ការចុះផ្សាយនេះបានឆ្លុះបញ្ចាំងពីចំណុចវិជ្ជមាន និងអវិជ្ជមានផងដែរ ហើយអត្ថបទសារព័ត៌មានដែលចុះផ្សាយចំនួន១៧១ករណីត្រូវបានជ្រើសរើសរួចបញ្ជូនទៅបណ្តាខណ្ឌរដ្ឋបាលព្រៃឈើដើម្បីបំភ្លឺ ព្រមទាំងបានបំភ្លឺមកវិញចំនួន៣៤ករណី។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៤-២០១៥ សរុបបានចំនួន១២.២៨៥តោន ស្មើ១០២,៣៨% នៃផែនការ១២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១១.៧១៥តោន

- នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៥ សរុបបានចំនួន១៧០.២៥០តោន ស្មើ៤៨,៦៤% នៃផែនការ៣៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៩.៧៥០តោន

- នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៥ សរុបបានចំនួន៤១.១៥៥តោន ស្មើ២៧,៤៤% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១៣.៨៤៥តោន(មូលហេតុនៃការថយចុះគឺបណ្តាលមកពីការប្រែប្រួលអាកាសធាតុ)។

#### ៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៥

- ក្នុងខែចំនួន៨.២៦៥តោន សរុបចំនួន៥១.៥០០តោន ស្មើ៤៦,៨២% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១.៥០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា សរុបបានចំនួន៦៣.៥៥០តោន ស្មើ៤៤,១៣% នៃផែនការ១៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន១៤.៥៥០តោន

- ការចិញ្ចឹមក្រពើ សរុបបានចំនួន១៣៥.៥០០ក្បាល ស្មើ៥៤,២០% នៃផែនការ២៥០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៣៤.៥០០ក្បាល

- ការភ្ញាស់កូនត្រីពូជ សរុបបានចំនួនប្រមាណ៨៥.០០០.០០០កូន ស្មើ៤៧,២២% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួនប្រមាណ៥.០០០.០០០កូន។

- បានប្រារព្ធទិវាមច្ឆជាតិ លើកទី១នៅអាងទឹកទួលព្រះឃ្លាំង ភូមិវត្ត ឃុំទួលព្រះឃ្លាំង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដោយបានលែងកូនត្រីចម្រុះជាង១លានក្បាល

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៤-២០១៥ សរុបបានចំនួន៣១.៥០០តោន ស្មើ៣៨,៤១% នៃផែនការ៨២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៥.៥០០តោន

- ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៥ សរុបបានចំនួន៥.៦០០តោន ស្មើ៧០% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន១០០តោន

- ការផលិតទឹកត្រី សរុបបានចំនួន៤០.០០០.០០០លីត្រ ស្មើ៨០% នៃផែនការ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៥.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ សរុបបានចំនួន៥.៣០០តោន ស្មើ៣៥,៣៣% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន២០០តោន

- ផលនេសាទកែច្នៃ សរុបបានចំនួន២.៧០០តោន ស្មើ៥៤% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- ក្នុងឆមាសទី១ ឆ្នាំ២០១៥នេះ សំណុំរឿងបទល្មើសជលផលសរុបចំនួន១.៦១៩ករណី ក្នុងនោះបទល្មើសទឹកសាប១.៥៥៨ករណី និងបទល្មើសសមុទ្រចំនួន៦១ករណី ដោយបានបញ្ជូនទៅតុលាការចំនួន៥៤ករណី ព្រមទាំងពិន័យអន្តរការណ៍ចំនួន២២៩ករណី ស្មើនឹងទឹកប្រាក់សរុបចំនួន៥៧៥.២០១.០០០រៀល

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង៣០៥.៩៦២ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន៤.៨៧៦មាត់ បង្គោល/ចម្រឹងចំនួន៣៣៣.០៦៤ដើម ឧបករណ៍ឆក់ត្រីចំនួន១.២៤២គ្រឿង សម្រាស់ចំនួន៦១.២០៦ម៉ែត្រក្រឡា របាំងព្រួលប្រវែង៦.៩០៨ម៉ែត្រ លបកែច្នៃ(កន្ទុយកណ្តុរ/ពោះវៀនជ្រូក)ចំនួន១៦១គ្រឿង និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន៣១.៩៩៨គ.ក្រ និងលែងកូនត្រីឆ្តោចំនួន១០.០០០ក្បាល។ សមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

### ៥.៦ ការប្រមូលចំណូល

- ចំណូលពីវិស័យជលផល សរុបបានចំនួន១.៧៦៩.៥៥៧.៥០០រៀល ស្មើ៥៨,៩៩% នៃផែនការ៣.០០០.០០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១៨៧.០៣៦.០៩៤រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចូលរួមប្រជុំនិងសិក្ខាសាលាផ្សេងៗសរុបចំនួន៦៩លើកនៅក្នុងប្រទេស និង០៧លើកនៅក្រៅប្រទេសដូចជា ប្រទេសថៃ ជប៉ុន ភូមា ឥណ្ឌូនេស៊ី អ៊ីតាលី និងឡាវ

- ធ្វើពិសោធន៍ចំនួន៦១ប្រភេទនៅ៤០៨កន្លែង ធ្វើអង្កេតបានចំនួន៨ប្រភេទ ដោយបានសម្ភាសន៍ជាមួយកសិករចំនួន៧០០គ្រួសារ

- ធ្វើការបែងចែកឯកសារបោះពុម្ពសរុបចំនួន៣.៥០០ច្បាប់